01391489

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គបុរេជំនុំជម្រះ**
Pre-Trial Chamber
Chambre Préliminaire

ឯកសារ D100/32/1/7

***តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ***

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣១)

**អង្គបុរេជំនុំជម្រះ**

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន** **ប្រធាន**
**ចៅក្រម** Olivier BEAUVALLET
**ចៅក្រម នេយ ថុល**
**ចៅក្រម** Kang Jin BAIK
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 02 / 2017
ម៉ោង (Time/Heure): 09:[illegible]
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ: កោសលុប**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលសុំដាក់បញ្ចូលឯកសាររឿងក្តី ០០៣ នៅក្នុងរឿងក្តី ០០២ (ឯកសារ D100/25 និង D100/29)**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី** [redacted]
អាង ឧត្តម

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

Michael G. KARNAVAS

ទី ស្រីណា

វ៉េន ពៅ

Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS

ជេត វណ្ណលី

ឡោ ជុនធី

Yiqiang LIU

ស៊ិន សុវ៉ន

Beini YE

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលសុំដាក់បង្ហាញឯកសាររឿងក្តី ០០៣ នៅក្នុងរឿងក្តី ០០២ (ឯកសារ D100/25 និង D100/29)" ដែលសហមេធាវីការពារក្តី [redacted] ("សហមេធាវីការពារក្តី" និង "ម្ចាស់បណ្តឹងឧទ្ធរណ៍") បានដាក់នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. **សេចក្តីផ្តើម**

1. បណ្តឹងឧទ្ធរណ៍នេះប្តឹងជំទាស់ដីកាសម្រេចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានចេញកាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ អនុញ្ញាតឱ្យដាក់បង្ហាញឯកសារទៅតាមសំណើសុំរបស់សហព្រះរាជអាជ្ញា ("ស.ព.ជ.អ") ទៅតាមទម្រង់បែបបទ និងការកំហិតដូចបានរៀបរាប់ ("ដីកាសម្រេចដែលត្រូវបានជំទាស់")[2]។

## II. **សាវតារនីតិវិធី**

2. នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ស.ព.ជ.អ បានដាក់សំណើសុំសហចៅក្រមស៊ើបអង្កេតឱ្យផ្តល់សិទ្ធិដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយចំនួន ១១ ច្បាប់ និងរបាយការណ៍ស្តីពីការស៊ើបអង្កេតចំនួនបីច្បាប់ពីក្នុងសំណុំរឿង ០០៣ ចូលក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ ("សំណើសុំលើកទី១")[3]។ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ មេធាវីការពារក្តីបានដាក់

---

[1] បណ្តឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលសុំដាក់បង្ហាញឯកសាររឿងក្តី ០០៣ នៅក្នុងរឿងក្តី ០០២ (ឯកសារ D100/25 និង D100/29) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ D100/32/1/1 ("បណ្តឹងឧទ្ធរណ៍")។

[2] ដីកាសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៣ ទៅក្នុងសំណុំរឿង ០០២ (ឯកសារ D100/25 និង D100/29) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ ឯកសារ D100/32 ("ដីកាសម្រេចដែលត្រូវបានជំទាស់")។

[3] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៣ ចូលទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D100/25 ("សំណើសុំលើកទីមួយ")។

ចម្លើយតបជំទាស់នឹងសំណើសុំលើកទី១[4] ហើយនៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ស.ព.ជ.អ បានដាក់ការឆ្លើយតបមកវិញ[5]។

3. នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៦ ស.ព.ជ.អ បានដាក់សំណើមួយទៀតសុំដាក់បង្ហាញកំណត់ហេតុនៃការស្ដាប់ចម្លើយចំនួនបីច្បាប់ថែមទៀត[6]។ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ មេធាវីការពារក្ដីបានដាក់ចម្លើយតបជំទាស់នឹងសំណើសុំលើកទី២[7]។

4. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ ស.ច.ស.អ បានចេញដីកាសម្រេចដែលត្រូវបានជំទាស់ដោយបានផ្ដល់សិទ្ធិអនុញ្ញាតឲ្យដាក់បង្ហាញឯកសារទាំងអស់ដែលបានស្នើសុំនៅក្នុងសំណុំរឿង ០០២ ទៅតាមទម្រង់បែបបទ និងការកំហិតដូចបានរៀបរាប់។ ដីកាសម្រេចដែលត្រូវបានជំទាស់មានជាភាសាខ្មែរនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦។

5. នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៦ មេធាវីការពារក្ដីបានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចដែលត្រូវបានជំទាស់ (“សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍”)[8] ហើយបណ្ដឹងឧទ្ធរណ៍ត្រូវបានដាក់នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦។ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ស.ព.ជ.អ បានដាក់សំណើសុំសិទ្ធិដាក់ចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍នេះជាសំណៅភាសា

---

[4] ចម្លើយតបរបស់ [redacted] ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនៃរឿងក្ដី ០០៣ នៅក្នុងរឿងក្ដី ០០២ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D100/27 (“ចម្លើយតបលើកទីមួយ”)។

[5] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ [redacted] ចំពោះការដាក់បង្ហាញឯកសារនានាដែលបានស្នើសុំ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D100/28 (“ការឆ្លើយតប”)។

[6] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៣ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ D100/29 (“សំណើសុំលើកទីពីរ”)។

[7] ចម្លើយរបស់ [redacted] តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសាររឿងក្ដី ០០៣ ទៅក្នុងរឿងក្ដី ០០២ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ D100/30 (“ចម្លើយតបលើកទីពីរ”)។

[8] សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្ដឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសាររឿងក្ដី ០០៣ នៅក្នុងរឿងក្ដី ០០២ (ឯកសារ D100/25 និង D100/29) ដែលបានដាក់នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៦ និងជូនដំណឹងនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ D100/32/1 (“សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍”)។

អង់គ្លេសជាមុនសិន ដោយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ ហើយក៏បានស្នើសុំពន្យារកាលបរិច្ឆេទកំណត់ដាក់ចម្លើយតបត្រឹមថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦។ អង្គបុរេជំនុំជម្រះបានយល់ព្រមតាមសំណើសុំនេះ[9]។ នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៦ ស.ព.ជ.អ បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍ ហើយសំណៅជាភាសាខ្មែរត្រូវបានជូនដំណឹងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៦ ("ចម្លើយតប")[10]។ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ មេធាវីការពារក្ដីបានដាក់ការឆ្លើយតបទៅនឹងចម្លើយតបរបស់ ស.ព.ជ.អ ("ការឆ្លើយតប")[11]។

## III. **ភាពអាចទទួលយកបាន**

### **១. សេចក្ដីសន្និដ្ឋាន**

6. មេធាវីការពារក្ដីសន្និដ្ឋានថា បណ្ដឹងឧទ្ធរណ៍នេះអាចទទួលយកបានអនុលោមតាមវិធាន ៧៤(៣)(ជ) នៃវិធានផ្ទៃក្នុង [12] ឬ ក្នុងករណីមានភាពសង្ស័យលើភាពអាចទទួលយកបានអនុលោមតាម

---

[9] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលក្នុងការឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ទៅនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលសុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ ទៅក្នុងសំណុំរឿង ០០២ (ឯកសារ D100/25 និង D100/29) ដែលបានដាក់នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ D100/32/1/2។ *សូមមើលផងដែរ* ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលក្នុងការឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ទៅនឹងដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៣ ចូលទៅក្នុងសំណុំរឿង ០០២ (ឯកសារ D100/25 និង D100/29) ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ D100/32/1/4។

[10] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណើសុំដាក់បង្ហាញឯកសារ D100/25 និង D100/29 ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D100/32/1/5 ("ចម្លើយតប")។

[11] ការឆ្លើយតបរបស់ [redacted] ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិចំពោះបណ្ដឹងឧទ្ធរណ៍របស់ [redacted] ជំទាស់នឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណើសុំដាក់បង្ហាញឯកសារ D100/25 និង D100/29 ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D100/32/1/6 ("ការឆ្លើយតប")។

[12] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១០។

*សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលសុំដាក់បង្ហាញឯកសាររឿងក្ដី ០០៣ ទៅក្នុងរឿងក្ដី ០០២ (ឯកសារ D100/25 និង D100/29)*

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

វិធាន ៧៤(៣)(ជ) នៃវិធានផ្ទៃក្នុងនោះ បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបានអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[13] ឬ ផ្អែកតាមការបកស្រាយក្នុងន័យទូលាយលើសិទ្ធិប្តឹងឧទ្ធរណ៍[14]។

7. ចំពោះភាពអាចទទួលយកបានអនុលោមតាមវិធាន ៧៤(៣)(ជ) នៃវិធានផ្ទៃក្នុង មេធាវីការពារក្តីសន្និដ្ឋានថា ដីកាសម្រេចដែលត្រូវបានជំទាស់ពាក់ព័ន្ធនឹងវិធានការការពារដោយហេតុថា៖ i) ស.ព.ជ.អ បានស្នើសុំដាក់បង្ហាញឯកសារដោយពុំចាំបាច់មានវិធានការការពារ ii) មេធាវីការពារក្តីអះអាងនៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងសំណើសុំលើកទី១ និងសំណើសុំលើកទី២ របស់ ស.ព.ជ.អ ថា ប្រសិនបើការដាក់បង្ហាញត្រូវបានអនុញ្ញាត ឯកសារទាំងឡាយគួរប្រើប្រាស់ដោយគោរពគោលការណ៍រក្សាការសម្ងាត់ ពោលគឺ ការប្រើប្រាស់រហស្សនាម ហើយនឹងការប្រើប្រាស់តែនៅក្នុងសវនាការអសាធារណៈបន្ថែមលើវិធានការការពារផ្សេងទៀតដែល ស.ច.ស យល់ឃើញថាចាំបាច់ ហើយ iii) នៅត្រង់កថាខណ្ឌ ៥៣ ដល់ កថាខណ្ឌ ៥៥ ស.ច.ស.អ "បានចេញសេចក្តីសម្រេចស្តីពីការអនុវត្តវិធានការការពារ"[15]។

8. ចំពោះភាពអាចទទួលយកបានអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងវិញ មេធាវីការពារក្តីសន្និដ្ឋានថា ដីកាសម្រេចដែលត្រូវបានជំទាស់រំលោភបំពានសិទ្ធិរបស់ [redacted] ទទួលបានសច្ចធារណ៍និរទោស ព្រមទាំងសិទ្ធិមានភាពឯកជន និងកេរ្តិ៍ឈ្មោះរបស់គាត់ ហើយព្យសនកម្មដែលបានកើតឡើងចេញពីការរំលោភសិទ្ធិទាំងនេះ "មិនអាចជួសជុលបាននៅពេលដែលឯកសារត្រូវបានដាក់បង្ហាញដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីនៅក្នុងរឿងក្តី ០០២ និងកាន់តែមានសភាពធ្ងន់ធ្ងរនៅពេលដែលឯកសារត្រូវបានប្រើប្រាស់នៅក្នុងកិច្ចដំណើរការនីតិវិធីសាធារណៈ"[16]។ មេធាវីការពារក្តីលើកឡើងបន្ថែមទៀតថា ប្រសិនបើបណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានទេនោះ [redacted] នឹងពុំទទួលបាន*ឧបាស្រ័យប្រកបដោយប្រសិទ្ធភាព* ពីព្រោះ "គ្មានផ្លូវដោះស្រាយផ្សេងទៀតសម្រាប់រូបគាត់ឡើយ"។ មេធាវីការពារក្តីបានអះអាងថា អនុលោមតាមមាត្រា ១៧(២) នៃកតិកា

---

[13] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១១ និងលេខយោងជើងទំព័រ ២៩ ដែលបានយោងលើ អបជ ០២/៧១។

[14] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៣។

[15] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១០ និងលេខយោងជើងទំព័រ ២៨។

[16] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១១។

សញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“កតិកាសញ្ញាអន្តរជាតិ”) ការអធិប្បាយទូទៅលេខ ១៦ នៃគណកម្មាធិការសិទ្ធិមនុស្ស “ជនគ្រប់រូបមានសិទ្ធិ *ឱ្យច្បាប់ការពារប្រឆាំងនឹងការជ្រៀតជ្រែក*ក្នុងជីវិតឯកជន និងកេរ្តិ៍ឈ្មោះ” ហើយ “រដ្ឋមានកាតព្វកិច្ចបង្កើតច្បាប់គ្រប់គ្រាន់ដើម្បី [ឱ្យបុគ្គលគ្រប់រូប] អាចការពារខ្លួនឯងប្រឆាំងនឹងការវាយប្រហារដោយខុសច្បាប់ដែលកើតឡើង និងទទួលបានដំណោះស្រាយយ៉ាងមានប្រសិទ្ធភាពប្រឆាំងនឹងជនដែលទទួលខុសត្រូវ”[17]។

9. ស.ព.ជ.អ ឆ្លើយតបថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបាននោះទេអនុលោមតាមវិធាន ៧៤(៣)(ជ) នៃវិធានផ្ទៃក្នុងដោយហេតុថា i) “តាមការអានប្រកបដោយភាពសមហេតុផលលើដីកាសម្រេចដែលរងការជំទាស់ពុំលើកឡើងអំពី “វិធានការការពារ” ឡើយ”[18] ii) មេធាវីការពារក្តីពុំបានស្នើសុំវិធានការការពារ *ដោយសារការបារម្ភពីការការពារសាក្សីឡើយ*[19] ហើយ iii) បណ្តឹងឧទ្ធរណ៍ពុំពាក់ព័ន្ធវិធានការការពារនោះទេ[20]។ ស.ព.ជ.អ ក៏បានច្រានចោលភាពអាចទទួលយកបានអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងពីព្រោះពុំមានការប៉ះពាល់លើសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[21]។ យោងតាម ស.ព.ជ.អ ការដាក់បង្ហាញឯកសារពីការស៊ើបអង្កេតលើសំណុំរឿង ០០៣ ទៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះសំណុំរឿង ០០២ ពុំមានអានុភាពប៉ះពាល់លើ [redacted] នោះឡើយដោយសារថា “វាពុំបន្ថែម ឬ បន្ថយភស្តុតាងប្រឆាំង [គាត់]”[22]។ ស.ព.ជ.អ រំលឹកបន្ថែមទៀតថា ដើម្បីអាចឱ្យបណ្តឹងឧទ្ធរណ៍ទទួលយកបានអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញថា ការអន្តរាគមន៍ចាំបាច់ត្រូវធ្វើឡើងដើម្បីទប់ស្កាត់ការខូចខាតដែលពុំអាចជួសជុលបាន[23]។ ស.ព.ជ.អ កត់សម្គាល់ថែមទៀតថា អង្គបុរេជំនុំជម្រះបានច្រានចោលជាឯកច្ឆន្ទមិនទទួលយកបណ្តឹងឧទ្ធរណ៍មួយទៀតដែល

---

[17] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១២។

[18] ចម្លើយតប កថាខណ្ឌ ៥។

[19] ចម្លើយតប កថាខណ្ឌ ៦ ដែលយោងលើវិធាន ២៩ និងវិធាន ៧៤(៣)(ជ) នៃវិធានផ្ទៃក្នុង។

[20] ចម្លើយតប កថាខណ្ឌ ៧។

[21] ចម្លើយតប កថាខណ្ឌ ៨។

[22] ចម្លើយតប កថាខណ្ឌ ៨។

[23] ចម្លើយតប កថាខណ្ឌ ៩ ដែលយោងលើយុត្តិសាស្ត្រនៃ អបជ។



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

បានប្តឹងអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងទាមទារអំពីការរំលោភបំពានសិទ្ធិសច្ចធារណ៍និរទោស[24]។

10. មេធាវីការពារក្តីឆ្លើយតបថា ពាក់ព័ន្ធនឹងភាពអាចទទួលយកបានអនុលោមតាមវិធាន ៧៤(៣)(ជ) នៃវិធានផ្ទៃក្នុង ករណីដែលថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិទាំងស្រុងថាតើសក្ខីកម្មនឹងផ្តល់ជូនក្នុងសវនាការអសាធារណៈដែរឬទេនោះ "មិនមែនមានន័យថា ដីកាសម្រេចរបស់ [ស.ច.ស.អ] ដែលនិយាយពីវិធានការការពារចាំបាច់សម្រាប់ការដាក់បង្ហាញភស្តុតាងសម្ងាត់ក្នុងរឿងក្តី ០០៣ *មិនមែនជាសេចក្តីសម្រេចស្តីពីវិធានការការពារតាមវិធាន ៧៤(៣)(ជ) នោះឡើយ*"[25] ហើយ "នៅពេលដែលចាត់វិធានការការពារជាលក្ខខណ្ឌនៃការដាក់បង្ហាញភស្តុតាង [...] [ស.ច.ស.អ] បំពេញកិច្ចអនុលោមតាមគោលការណ៍ដែលចូសបញ្ជាក់ក្នុងវិធាន ២៩"[26]។ មេធាវីការពារក្តីអះអាងបន្ថែមទៀតថា "ចេតនានៅពីក្រោយសំណើរបស់ភាគីសុំវិធានការការពារគឺមិនពាក់ព័ន្ធនឹងការសម្រេចថាតើសេចក្តីសម្រេចទាក់ទង ឬ មិនទាក់ទងនឹងវិធានការការពារឡើយ"[27]។ នៅក្នុងបណ្តឹងឧទ្ធរណ៍ មេធាវីការពារក្តីបានឆ្លើយតបទៅនឹង "កំហុសក្នុងការអនុវត្តវិធាន ៥៦ និងក្នុងការកំណត់និយមន័យពាក្យថា "សាធារណៈ" ដែលទាក់ទងនឹងការចាត់វិធានការការពារ" និង "ផលប៉ះពាល់ដល់ការសម្រេចរបស់គាត់ដែលថាតើវិធានការការពារមានលក្ខណៈចាំបាច់ ឬ យ៉ាងណា"[28]។ ចំពោះភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ផ្ទុយពីការលើកឡើងរបស់ ស.ព.ជ.អ ថា អ.ប.ជ ធ្លាប់បានច្រានចោលទឡ្ហីករណ៍ស្រដៀងគ្នា

---

[24] ចម្លើយតប កថាខណ្ឌ ១០ ដែលយោងលើរឿងក្តី ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("រឿងក្តី ០០៤") (អ.ប.ជ ២៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើចម្លើយតបរបស់ [redacted] D193/47, D193/49, D193/51, D193/53, D193/56 និង D193/60 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ("សាលដីកាលើរឿងក្តី ០០៤ (អ.ប.ជ ២៥)") កថាខណ្ឌ ២៣ ដល់ កថាខណ្ឌ ២៤។

[25] ការឆ្លើយតប កថាខណ្ឌ ២។

[26] ការឆ្លើយតប កថាខណ្ឌ ៣។

[27] ការឆ្លើយតប កថាខណ្ឌ ៣។

[28] ការឆ្លើយតប កថាខណ្ឌ ៤ *ដែលយោងលើ* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៥ ដល់ កថាខណ្ឌ ៣៩។ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់* [redacted] *ជំទាស់ដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលសុំដាក់បង្ហាញឯកសាររឿងក្តី ០០៣ នៅក្នុងរឿងក្តី ០០២ (ឯកសារ D100/25 និង D100/29)*

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ជាឯកច្ឆ័ន្ទ មេធាវីការពារក្តីសំណូមពរឱ្យអង្គបុរេជំនុំជម្រះពិនិត្យ "ទៅតាមករណីនីមួយៗជាក់ស្តែង" ហើយមេធាវីការពារក្តីតវ៉ាថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន[29]។

## ២. សេចក្តីសន្និដ្ឋាន

### *២.១ តើបណ្តឹងឧទ្ធរណ៍អាចទទួលយកបានអនុលោមតាមវិធាន ៧៤(៣)(ជ) ដែរឬទេ?*

11. ជាដំបូង អង្គបុរេជំនុំជម្រះលើកឡើងយោងលើបទប្បញ្ញត្តិនៅក្នុងវិធាន ៧៤(៣)(ជ) នៃវិធានផ្ទៃក្នុង ដែលចែងដូចខាងក្រោមថា៖

> "៣. ជនត្រូវចោទ ឬ ជនជាប់ចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដូចខាងក្រោម៖
>
> ជ- ទាក់ទងទៅនឹងវិធានការការពារ "[30]

12. នៅពេលលើកឡើងថា ដីកាសម្រេចដែលត្រូវបានជំទាស់ពាក់ព័ន្ធនឹងវិធានការការពារ មេធាវីការពារក្តីបានលើកឡើងយោងលើកថាខណ្ឌ ៥៣ ដល់ កថាខណ្ឌ ៥៥ ដែលលើកឡើងថា៖

> "៥៣. ទាំងឯកសារដែលបានស្នើសុំលើកទីមួយ និងឯកសារដែលបានស្នើសុំលើកទីពីរអាចត្រូវបានដាក់បង្ហាញ និងត្រូវបានដាក់សាក្សីនេះនៅក្នុងប្រភេទ ក។
>
> ៥៤. ទាក់ទិនសំណើរបស់ ស.ព.អ ដែលថាភស្តុតាងទាំងអស់គួរត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងតុលាការជាសាធារណៈដោយពុំចាំបាច់ប្រើរហស្សនាម មានតែសាក្សីដូចខាងក្រោមប៉ុណ្ណោះដែលមិនត្រូវការវិធានការការពារអត្តសញ្ញាណរបស់ពួកគាត់ ឬ ខ្លឹមសារនៃភស្តុតាងរបស់ពួកគាត់ ដោយហេតុថា ពួកគាត់បានផ្តល់ចម្លើយពីពេលមុនក្នុងសំណុំរឿង ០០២ ដែលស្ថិតក្នុងសំណុំរឿងនោះ និង/ឬ បានផ្តល់សក្ខីកម្មពីពេលមុនក្នុងសំណុំរឿង ០០២ ដោយមិនប្រើរហស្សនាម៖ [...]។
>
> ៥៥. ស.ព.អ ពុំបានធ្វើទឡ្ហីករណ៍ ឬ ផ្តល់ព័ត៌មានគាំទ្រអំពីមូលហេតុដែលពុំចាំបាច់ប្រើរហស្សនាមទាក់ទងសាក្សីសេសសល់ពីឯកសារដែលបានស្នើសុំលើកទីមួយ និងទីពីរ។"

---

[29] ការឆ្លើយតប កថាខណ្ឌ ៥។

[30] អ.វ.ត.ក វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិសោធនកម្មនៅថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៥ (វិធានផ្ទៃក្នុង)។

*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលសុំដាក់បង្ហាញឯកសាររឿងក្តី ០០៣ នៅក្នុងរឿងក្តី ០០២ (ឯកសារ D100/25 និង D100/29)*

ECCC C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

13. មេធាវីការពារក្តីបានបង្ហាញការយល់ឃើញដូចបានលើកឡើងនៅក្នុងការឆ្លើយតបថា "នៅពេលដែលចាត់វិធានការការពារជាលក្ខខណ្ឌនៃការដាក់បង្ហាញភ័ស្តុតាង ស.ច.ស.អ បំពេញកិច្ចអនុលោមតាមគោលការណ៍ដែលគូសបញ្ជាក់ក្នុងវិធាន ២៩"។

14. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងកថាខណ្ឌដែលបានលើកឡើង ដីកាសម្រេចដែលត្រូវបានជំទាស់ដំបូងសម្រេចថា ឯកសារទាំងឡាយ "អាចដាក់បង្ហាញបាន" ហើយយោងតាមដីកាសម្រេចនេះ ស.ច.ស.អ ក៏ឆ្លើយតបទៅនឹងការលើកឡើងរបស់ ស.ព.ជ.អ អំពីគម្រូបែបបទនៃការដាក់បង្ហាញ*នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ*។ អង្គបុរេជំនុំជម្រះសូមរំលឹកឡើងវិញថា នៅពេលសម្រេចលើបណ្តឹងឧទ្ធរណ៍មុន[31] ដែលបណ្តឹងឧទ្ធរណ៍នេះលើកឡើងបញ្ហាពាក់ព័ន្ធនឹងផ្នែកមួយនៃដីកាសម្រេចមួយទៀតរបស់ ស.ច.ស.អ ហើយក៏មើលឃើញគម្រូបែបបទសម្រាប់ការដាក់បង្ហាញផងដែរនោះ[32] អង្គបុរេជំនុំជម្រះបានសម្រេចថា "ដីកាដែលរងការជំទាស់*ជាប់ទាក់ទងនឹងបែបបទនៃការដាក់បង្ហាញ*ព័ត៌មានសម្ងាត់ពីកិច្ចស៊ើបសួរដែលកំពុងធ្វើឡើងអនុលោមតាម*វិធាន ៥៦*"[33]។ អង្គបុរេជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា "នៅក្នុងដីកាសម្រេចដាក់បង្ហាញឯកសារមួយចំនួន [ស.ច.ស.អ] "*បានស្នើសុំ*" ឱ្យអង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូលធានាការអនុវត្ត "លក្ខខណ្ឌ" និង "ការដាក់កំហិត" ដែលបានកំណត់លើការដាក់បង្ហាញឯកសារ"[34]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅពេលធ្វើការពិចារណាសម្រេចនៅក្នុងដីកាសម្រេចស្តីពីការដាក់បង្ហាញអំពីគម្រូបែបបទនៃការដាក់បង្ហាញដែលត្រូវបានអនុញ្ញាត ស.ច.ស.អ មានមុខងារត្រឹមការផ្តល់គោលការណ៍ណែនាំដែលខ្លួនបានដឹងជូនអង្គជំនុំ

---

[31] សំណុំរឿង០០៤ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងការផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះនៅក្នុងសវនាការអសាធារណៈ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D309/1។

[32] សំណុំរឿង០០៤ ដីកាដកការកោសលប់ពីឯកសារនៃសំណុំរឿង ០០៤ ដែលត្រូវបានដាក់បង្ហាញពីពេលមុនទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D193/66 កថាខណ្ឌ ៧(ឃ)។

[33] សំណុំរឿង ០០៤ (អ.ប.ជ ២៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងការផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះនៅក្នុងសវនាការអសាធារណៈ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ D309/6 ("សាលដីកាលើរឿងក្តី ០០៤ (អ.ប.ជ ០៤/២៦)") កថាខណ្ឌ ២៩។

[34] សាលដីកាលើរឿងក្តី ០០៤ (អ.ប.ជ ០៤/២៦) កថាខណ្ឌ ៣០។

01391499



ជម្រះសាលាដំបូងដែលមានយុត្តាធិការផ្តាច់មុខក្នុងការចេញសេចក្តីសម្រេចលើសក្ខីកម្មនៅក្នុងសវនាការអសាធារណៈ[35]។

15. អង្គបុរេជំនុំជម្រះយល់ឃើញថា នៅពេលធ្វើការពិចារណាសម្រេចនៅក្នុងដីកាសម្រេចស្តីពីការដាក់បង្ហាញអំពីគម្រូបែបបទនៃការដាក់បង្ហាញដែលត្រូវបានអនុញ្ញាត ស.ច.ស.អ ពុំបាន "បំពេញកិច្ចអនុលោមតាមគោលការណ៍នៃវិធាន ២៩ នៃវិធានផ្ទៃក្នុង" ដូចបានលើកឡើងដោយមេធាវីការពារក្តីនោះទេ។ អនុលោមតាមវិធាន ២៩ នៃវិធានផ្ទៃក្នុង ស.ច.ស អាចបង្គាប់វិធានការធានាការការពារជនរងគ្រោះ និងសាក្សី។ "វិធានការការពារ" និង "គម្រូបែបបទនៃការដាក់បង្ហាញ" មានគោលបំណងធានាជាពិសេសលើតម្លៃ និងផលប្រយោជន៍ខុសៗគ្នាពីព្រោះថា គម្រូបែបបទនៃការដាក់បង្ហាញមានគោលបំណងម្យ៉ាងគឺរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរដើម្បី "ធានាសិទ្ធិ និងផលប្រយោជន៍របស់ភាគី" [36] ហើយវិធានការការពារមានគោលបំណងម្យ៉ាងទៀតគឺការពារជនរងគ្រោះ និងសាក្សីនៅពេលមានហានិយភ័យថានឹងមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ជីវិត និងសុខភាពរបស់ពួកគេ និងគ្រួសារ[37]។ ទោះបីជាដីកាសម្រេចរបស់ ស.ច.ស.អ ដែលបានអនុញ្ញាតឲ្យដាក់បង្ហាញមានភាពចាំបាច់តាមកាតព្វកិច្ចផ្លូវច្បាប់ជួយដល់ដំណើរការស្វែងរកការពិតរបស់*ស្ថាប័នតុលាការ*មួយទៀតនៃ អ.វ.ត.ក ក៏ដោយ ការពិចារណាសម្រេចរបស់ ស.ច.ស.អ លើអ្វីដែលនឹងចាត់ទុកថាជាគម្រូបែបបទសមស្របបំផុតសម្រាប់ការដាក់បង្ហាញដែលត្រូវបានអនុញ្ញាតនោះបានអនុវត្តតាមគោលការណ៍ណែនាំស្តីពីលក្ខខណ្ឌត្រូវធានាការរក្សាការសម្ងាត់នៃការស៊ើបអង្កេតដូចបានកំណត់នៅក្នុងវិធាន ៥៦ នៃវិធានផ្ទៃក្នុង[38]។ អាស្រ័យហេតុនេះ ពាក្យថា "វិធានការការពារ" នៅក្នុងវិធាន ៧៤(៣)(ជ) នៃវិធានផ្ទៃក្នុងត្រូវបកស្រាយឲ្យស្របតាមបទប្បញ្ញត្តិនៃវិធាន ២៩(៤) និង(៨) នៃវិធានផ្ទៃក្នុង។ សំណើសុំ "គម្រូបែបបទនៃការដាក់បង្ហាញ" ពី ស.ច.ស.អ ដើម្បីជូនដំណឹង

---

[35] *ដូចខាងលើ*។

[36] វិធាន ៥៦(១) នៃវិធានផ្ទៃក្នុង។

[37] វិធាន ២៩(៣) នៃវិធានផ្ទៃក្នុង។

[38] សាលដីកាលើរឿងក្តី ០០៤ (អ.ប.ជ ០៤/២៦) កថាខណ្ឌ ២៩ និងកថាខណ្ឌ ៣២។

ដល់អង្គជំនុំជម្រះត្រូវបញ្ជាក់ទៅតាមកាតព្វកិច្ចរបស់ ស.ច.ស.អ អនុលោមតាមវិធាន ៥៦ នៃវិធានផ្ទៃក្នុងដើម្បីរក្សាការសម្ងាត់នៃការស៊ើបអង្កេត ហើយពុំបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍នោះឡើយ។

16. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះពុំពិនិត្យឃើញមាន "ទំនាក់ទំនង" រវាង "វិធានការការពារ" និង "ដីកាសម្រេចរបស់ ស.ច.ស.អ" ស្តីពីការដាក់បង្ហាញ ឬ បែបបទនៃការដាក់បង្ហាញដែលនាំឱ្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបែបនេះស្ថិតនៅក្នុងវិសាលភាពនៃវិធាន ៧៤(៣)(ជ) នៃវិធានផ្ទៃក្នុងនោះឡើយ[39]។

## *២.២ តើបណ្តឹងឧទ្ធរណ៍អាចទទួលយកបានអនុលោមតាមវិធាន ២១ ដែរឬទេ?*

17. មេធាវីការពារក្តីសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបានអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ឬ យោងតាមការបកស្រាយក្នុងន័យទូលាយលើសិទ្ធិប្តឹងឧទ្ធរណ៍អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះបានយោងលើបទប្បញ្ញត្តិក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ហើយអង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចនាពេលមុនរួចហើយថា វិធាន ២១ នៃវិធានផ្ទៃក្នុងពុំបានផ្តល់សិទ្ធិដោយស្វ័យប្រវត្តិក្នុងការប្តឹងឧទ្ធរណ៍ដើម្បីលើកឡើងអំពីបញ្ហានៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះឡើយ។ ដើម្បីអាចឱ្យអង្គបុរេជំនុំជម្រះអនុវត្តយុត្តាធិការធ្វើបណ្តឹងឧទ្ធរណ៍អនុលោមតាមវិធាននេះបាន ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញថា នៅក្នុងកាលៈទេសៈជាក់លាក់នៃរឿងក្តីដែលប្រឈម អង្គបុរេជំនុំជម្រះចាំបាច់ត្រូវធ្វើការអន្តរាគមន៍ដើម្បីទប់ស្កាត់ការខូចខាតដែលមិនអាចជួសជុលបានលើភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬ សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍[40]។

---

[39] សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធិ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ៧២ កថាខណ្ឌ ៧៣។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30។ សូមមើលផងដែរ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៥ ដែលបានយោងនៅក្នុងលេខយោងជើងទំព័រ ៣៤ លើសាលដីកា អ.ប.ជ D239/I/8។

[40] សំណុំរឿង០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ("រឿងក្តី ០០២") (អ.ប.ជ៣១) សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ ក.ស.ច.ស លើសំណើរបស់លោក *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់* [redacted] *ជំទាស់ដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលសុំដាក់បង្ហាញឯកសាររឿងក្តី ០០៣ នៅក្នុងរឿងក្តី ០០២ (ឯកសារ D100/25 និង D100/29)*

18. ចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្តីថា ដីកាសម្រេចដែលត្រូវបានជំទាស់រំលោភបំពានសិទ្ធិរបស់ [redacted] អង្គបុរេជំនុំជម្រះសូមរំលឹកជាមុនថា អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចថាវាមិនសមស្របក្នុងការបកស្រាយមាត្រា ៨៣ និងមាត្រា ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាន ២១ ព្រមទាំងវិធាន ៥៦(១) នៃវិធានផ្ទៃក្នុងថាជាការផ្តល់សិទ្ធិឱ្យជនត្រូវចោទមាន "សិទ្ធិជាប់មកជាមួយ" ក្នុងការទទួលបានសុចរិតភាពនៅក្នុងដំណើរការស៊ើបអង្កេត ការស៊ើបអង្កេតសម្ងាត់ ឬ ការការពារកេរ្តិ៍ឈ្មោះរបស់ខ្លួន[41]។ អង្គបុរេជំនុំជម្រះក៏បានច្រានចោលការអះអាងផងដែរថា ដីកាសម្រេចស្តីពីការដាក់បង្ហាញបានរំលោភបំពានសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានសច្ចធារណ៍និរទោសដោយពុំអាចជួសជុលបាន[42]។ ដូច្នេះ អង្គបុរេជំនុំជម្រះពុំជឿជាក់តាមទឡ្ហីករណ៍របស់មេធាវីការពារក្តីទេថា សិទ្ធិរបស់ [redacted] រួមទាំងសិទ្ធិទទួលបានភាពឯកជន កំពុងប្រឈមនឹងការខូចខាតដែលមិនអាចជួសជុលបានប្រសិនបើសម្ភារៈនានាត្រូវបានដាក់បង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ករណីត្រឹមថា ស.ច.ស.អ អនុញ្ញាតឱ្យដាក់បង្ហាញឯកសារនានាពុំគ្រប់គ្រាន់ក្នុងការសន្និដ្ឋានថា សិទ្ធិរបស់ [redacted] នឹងរងការខូចខាតមិនអាចជួសជុលបាននៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្រោយពីពិចារណាលើសមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបើកកិច្ចដំណើរការនីតិវិធីផ្នែកខ្លះ *ជាអសាធារណៈ*អនុលោមតាមវិធាន ២៩(៤)(ង) និងវិធាន ៧៩(៦)(ខ)នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះសូមរំលឹកថា អង្គបុរេជំនុំជម្រះគ្មានយុត្តាធិការពិចារណាសម្រេចលើបញ្ហាឧបមាណវិធីនោះ

អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភ័ស្តុតាង និងការសំអាងទៅលើភ័ស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៩ ឯកសារ D130/7/3/5 កថាខណ្ឌ ៣៩។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D205/1/1/2 ; សាលដីកាលើសំណុំរឿង ០០៤, អ.ប.ជ ១១, កថាខណ្ឌ ៧; សាលដីកាលើសំណុំរឿង ០០៤, អ.ប.ជ ២៥, កថាខណ្ឌ ២១។

[41] សាលដីកាលើរឿងក្តី ០០៤ (អ.ប.ជ ២៥) កថាខណ្ឌ ២៣។

[41] សាលដីកាលើរឿងក្តី ០០៤ (អ.ប.ជ ២៥) កថាខណ្ឌ ២៣។

[42] សាលដីកាលើរឿងក្តី ០០៤ (អ.ប.ជ ២៥) កថាខណ្ឌ ២៤។

*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលសុំដាក់បង្ហាញឯកសាររឿងក្តី ០០៣ នៅក្នុងរឿងក្តី ០០២ (ឯកសារ D100/25 និង D100/29)*

E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ទេ[43] ហើយផលប៉ះពាល់ដែលការដាក់បង្ហាញកើតមានលើសិទ្ធិរបស់ [redacted] នៅគ្រាន់តែជាការស្មានៗសុទ្ធសាធនៅក្នុងដំណាក់ការនេះ។

19. ចំពោះការអះអាងថា ប្រសិនបើបណ្ដឹងឧទ្ធរណ៍រកឃើញថាមិនអាចទទួលយកបាន [redacted] ក៏នឹងទទួលរងពីការខ្វះនូវឧបាស្រ័យមួយប្រកបដោយប្រសិទ្ធភាពពីព្រោះថា អនុលោមតាមកតិកាសញ្ញាអន្តរជាតិ [redacted] មានសិទ្ធិ *ទទួលបានការការពារដោយច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែកលើសិទ្ធិ*ទទួលបានភាពឯកជន និងកេរ្តិ៍ឈ្មោះ អង្គបុរេជំនុំជម្រះយល់ឃើញដូចការកត់សម្គាល់របស់មេធាវីការពារក្ដីផងដែរថា ពាក្យពេចន៍នៅក្នុងមាត្រា ១៧ នៃកតិកាសញ្ញាអន្តរជាតិ[44] ចែងលើកឡើងថា មាត្រានេះអនុញ្ញាតឱ្យមានការជ្រៀតជ្រែកភាពឯកជនដរាបណាវាពុំធ្វើឡើង "តាមទំនើងចិត្ត" ឬ "ដោយខុសច្បាប់"[45]។ ពាក្យថា "ដោយខុសច្បាប់" មានន័យថា គ្មានការជ្រៀតជ្រែកអាចធ្វើឡើងនោះទេលើកលែងតែនៅក្នុងករណីនានាដែលចែងកំណត់ទុកជាមុនដោយច្បាប់[46]។ វាក្យស័ព្ទ "ការជ្រៀតជ្រែកតាមទំនើងចិត្ត" ក៏អាចគ្របដណ្ដប់លើការជ្រៀតជ្រែកដែលអនុញ្ញាតតាមច្បាប់ ហើយទស្សនទាននៃ "ទំនើងចិត្ត" មានចេតនាធានាថា សូម្បីការជ្រៀតជ្រែកដែលចែងអនុញ្ញាតដោយច្បាប់គួរមានលក្ខណៈសមហេតុផលនៅក្នុងកាលៈទេសៈពិសេសនានា[47]។ ចំណុចទីមួយ អង្គបុរេជំនុំជម្រះសូមរំលឹកថា ច្បាប់ជាធរមានពុំផ្ដល់សិទ្ធិឱ្យជនត្រូវចោទមាន "សិទ្ធិជាប់មក

---

[43] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D117/1/1/2 កថាខណ្ឌ ១៥; សាលដីកាលើសំណុំរឿង ០០៤, អ.ប.ជ ១១។

[44] មាត្រា ១៧ នៃកតិកាសញ្ញាអន្តរជាតិចែងថា៖ "១. គ្មានជនណាម្នាក់ត្រូវបានទទួលរងនូវការជ្រៀតជ្រែកតាមទំនើងចិត្ត ឬ ខុសច្បាប់លើភាពឯកជន គ្រួសារ ផ្ទះសម្បែង ឬ ការឆ្លើយឆ្លង ហើយនឹងការវាយប្រហារខុសច្បាប់លើកត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួននោះឡើយ។ ២. ជនគ្រប់រូបមានសិទ្ធិទទួលបានការការពារដោយច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬ ការវាយប្រហារបែបនេះ"។

[45] សូមមើលផងដែរបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣០ និងកថាខណ្ឌ ៣១ *ដែលបានយោងលើ* កតិកាសញ្ញាអន្តរជាតិ យុត្តិសាស្ត្រតុលាការ ICC និងគណៈកម្មាធិការសិទ្ធិមនុស្សអឺរ៉ុប លើចំណុចនេះ។

[46] អធិប្បាយទូទៅនៃកតិកាសញ្ញាអន្តរជាតិលេខ ១៦ កថាខណ្ឌ ៣។ សូមមើលផងដែរ បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣១។

[47] អធិប្បាយទូទៅនៃកតិកាសញ្ញាអន្តរជាតិលេខ ១៦ កថាខណ្ឌ ៤។ សូមមើលផងដែរ បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣១។

*សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលសុំដាក់បង្ហាញឯកសាររឿងក្ដី ០០៣ នៅក្នុងរឿងក្ដី ០០២ (ឯកសារ D100/25 និង D100/29)*

ជាមួយ” ក្នុងការទទួលបានការការពារកេរ្តិ៍ឈ្មោះនោះទេ[48]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ផងដែរថា ទោះក្នុងករណីណាក៏ដោយ យើងពុំឃើញមានភ័ស្តុតាងជាក់ស្តែងបង្ហាញនូវព្យសនកម្មដែលបានបណ្តាលមកពីការដាក់បង្ហាញកើតមានចំពោះសិទ្ធិទទួលបានភាពឯកជន និងកេរ្តិ៍ឈ្មោះរបស់ [redacted] នោះឡើយ[49]។ ចំណុចទីពីរ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ដីកាសម្រេចដែលត្រូវបានជំទាស់ត្រូវបានចេញដោយស្ថាប័នតុលាការមានសមត្ថកិច្ចផ្អែកតាមច្បាប់តាមរយៈដំណើរការតទល់ចំពោះមុខ [50] ហើយត្រូវបានសម្រេចយ៉ាងសមហេតុផលក្នុងគោលបំណងស្របច្បាប់មួយគឺដើម្បីបំពេញបេសកកម្មការក្នុងការស្វែងរកការពិតដោយស្ថាប័នតុលាការមួយផ្សេងនៅ អ.វ.ត.ក។ ដូច្នេះ ដីកាសម្រេចនេះពុំត្រូវបានចេញតាមទំនើងចិត្តនោះឡើយ។

20. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ឬ អនុលោមតាមការបកស្រាយក្នុងន័យទូលាយលើសិទ្ធិប្តឹងឧទ្ធរណ៍អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។

## ៣. សេចក្តីសន្និដ្ឋាន

21. យោងតាមសំអាងហេតុទាំងអស់នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានអនុលោមតាមវិធាន ៧៤(៣)(ជ) វិធាន ២១ នៃវិធានផ្ទៃក្នុង ឬ ដោយផ្អែកលើការបកស្រាយក្នុងន័យទូលាយលើសិទ្ធិប្តឹងឧទ្ធរណ៍អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងនោះទេ។

## IV. សេចក្តីសម្រេច

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

[48] អ.ប.ជ ០៤/២៥ កថាខណ្ឌ ២៣។

[49] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣២ និងលេខយោងជើងទំព័រ ៦៦ *ដែលបានយោងលើ*ឯកសារ D114/143 និង ឯកសារ D114/151។

[50] *សូមមើល* ចម្លើយតបរបស់មេធាវីការពារក្តី ឯកសារ D100/27 និងឯកសារ D100/30។

**ច្រានចោល**បណ្តឹងឧទ្ធរណ៍នេះដោយសារបណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបាន។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១៧**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន៉ី ធុល** **Kang Jin BAIK** **ហួត វុទ្ធី**